នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Jun-2019, 14:53
CMS/CFO: Sann Rada

ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

## សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Martin KAROPKIN
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**ចម្លងជូន:**
**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន
**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក លីវ សុវណ្ណ
លោកស្រី Doreen CHEN
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

# សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ

១. អនុលោមតាមមាត្រា ១៧*ថ្មី និង* ៣៦*ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[1] និងវិធាន ១០៥ និង ១០៦ នៃវិធានផ្ទៃក្នុង[2] សហព្រះរាជអាជ្ញាដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនេះដោយកំណត់ ទទ្បីករណ៍មួយជាមូលហេតុនៃបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុង សំណុំរឿង ០០២/០២[3]។

២. សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និង/ឬ អង្គហេតុ[4] ដែលសន្និដ្ឋានថា ជនរងគ្រោះជាបុរសនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានបង្ខិតបង្ខំឲ្យរួម ភេទ ដោយមិនមានការព្រមព្រៀងដោយស្ម័គ្រចិត្ត មិនមែនជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត។ កំហុសនេះបណ្តាលមកពីការសម្រេចផ្នែកអង្គហេតុ និង/ឬអង្គច្បាប់ខុសរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា ទោះបីជារកឃើញថា បុរសបាន ទទួលរងនូវអំពើហិង្សាផ្លូវភេទដែលផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដោយ ក៏ធាតុផ្សំនៃអំពើ អមនុស្សធម៌ផ្សេងៗទៀត មិនត្រូវបានរកឃើញឡើយសម្រាប់ជនរងគ្រោះទាំងនេះ ពីព្រោះវាមិន អាចឈានទៅដល់ការសន្និដ្ឋានមួយអំពីភាពធ្ងន់ធ្ងរនៃការឈឺចាប់ផ្នែករាងកាយ និងផ្លូវចិត្ត[5]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

---

[1] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុង រយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ នស/រកម/១០០៤/០០៦ ថ្ងៃទី២៧ តុលា ឆ្នាំ២០០៤(“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”)។

[2] វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិ.សោធ.លើកទី៩ ថ្ងៃទី១៦ មករា ឆ្នាំ២០១៥ (“វិធានផ្ទៃក្នុង”)។

[3] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (“សាលក្រម”)។

[4] *សូមមើលដោយឡែក* ឯកសារ **E465** សាលក្រម, កថាខណ្ឌ ៧៣១, ៣៧០១។ កំហុសអង្គច្បាប់ និងអង្គហេតុទាំងនេះធ្វើឲ្យ មោឃៈនូវសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងថាតើអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានប្រព្រឹត្ត ប្រឆាំងនឹងជនរងគ្រោះជាបុរសចំពោះការរួមភេទដោយបង្ខំ នៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយដែលកំហុស ទាំងនោះនាំឲ្យមានការខុសឆ្គងរបស់តុលាការ ទាក់ទងទៅនឹងរឿងដូចគ្នា។ *សូមមើល* វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។

[5] *សូមមើលដោយឡែក* ឯកសារ **E465** សាលក្រម, កថាខណ្ឌ ៣៧០១។